**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**
**សំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ២៥៥**
**ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២**
**សាលដីកាលេខ: ៤៦៥ (ឧ)**
**ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២**

17-10-22

# សាលដីកា

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានធ្វើការបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

<u>ក្រឡាបញ្ជីសវនាការ</u>

លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ២៥៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង មានដូចខាងក្រោម៖

**-ជនជាប់ចោទ៖**

១. ឈ្មោះ [redacted]យ៉ុំ ភេទស្រី អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ កម្រិតវប្បធម៌ថ្នាក់ទី ១ចាស់ កើតនៅភូមិព្រៃវែង ឃុំសំរោងយា ស្រុកថ្មពួក ខេត្តសៀមរាប លំនៅបច្ចុប្បន្ននៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ប្តីឈ្មោះ [redacted] មានកូន០៧នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុន គ្មាន។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] ពេទ្យ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងម៉ូតូ កម្រិត



Scanned with CamScanner

វប្បធម៌ថ្នាក់ទី៧ ទីកន្លែងកំណើតនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted]ានកូន ឪពុកឈ្មោះ [redacted](ស) ម្តាយ ឈ្មោះ [redacted](រ) ទោសពីមុន គ្មាន ។(ក្រៅឃុំ)

៣. ឈ្មោះ [redacted] ប៉ោះ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរចាក់ធុងបាស កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន នៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ប្រពន្ធឈ្មោះ[redacted] មានកូន០២នាក់ ឪពុកឈ្មោះ [redacted](ស) ម្តាយ ឈ្មោះ[redacted](រ) ទោសពីមុន គ្មាន ។(ក្រៅឃុំ)

៤. ឈ្មោះ[redacted] ម៉ាប់ ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរចាក់ធុងបាស កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន នៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted](រ) ទោសពីមុន គ្មាន។(ក្រៅឃុំ)

៥. ឈ្មោះ [redacted]ង៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងម៉ូតូ កម្រិតវប្បធម៌ថ្នាក់ទី៣ ទីកន្លែងកំណើតនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ[redacted]រ) ទោសពីមុន គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ ហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥៣នៃច្បាប់ ភូមិបាល។

**-ដើមបណ្តឹងរដ្ឋប្បវេណីៈ**

ឈ្មោះ[redacted]សារ៉េត ភេទស្រី កើតឆ្នាំ១៩៦១ សញ្ជាតិខ្មែរ កើតនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប លំនៅបច្ចុប្បន្នភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប។

**អំពីអង្គហេតុ**

កាលឆ្នាំ១៩៩៧ ឈ្មោះ [redacted]សារេត បានគ្រប់គ្រងដីចំនួន ០១កន្លែង ដែលជាកេរ្តិ៍ជូនតាគាត់ ដែលមានព្រំប្រទល់ខាងកើតទល់នឹងថ្នល់ ខាងលិចទល់នឹងឈ្មោះ [redacted]សារឿ ខាងជើងទល់នឹងផ្លូវលំ និងខាងត្បូងទល់នឹង ឈ្មោះ[redacted]ខ្លាំង មានទំហំប្រហែល ២០៤០ម៉ែត្រការ៉េ ដែលស្ថិតនភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប។ នៅក្នុងឆ្នាំ១៩៨២ ឈ្មោះ[redacted]ស៊ី ដែលមានដីនៅព្រំជាប់នឹងឈ្មោះ [redacted] សារេត បានសុំដីនោះដើម្បីធ្វើស្រែចំនួន ០៣ឆ្នាំ បន្ទាប់ពីឈ្មោះ [redacted]ស៊ី ឈប់ធ្វើស្រែឈ្មោះ[redacted]សារេត បានធ្វើស្រែបន្តរហូតដល់ឆ្នាំ២០២០។ ក្រោយមកក៏មានអង្គការបន្ទាយស្រីបានស្នើសុំដីឈ្មោះ[redacted]សារេត ដើម្បីបណ្តុះកូនឈើទុកចែកឱ្យអ្នកភូមិ។ នៅពេលអង្គការបានបញ្ចប់គម្រោងឈ្មោះ [redacted] សារេត ក៏បាន គ្រប់គ្រងដីនេះវិញ។ នៅក្នុងឆ្នាំ២០០៧ កូនរបស់ឈ្មោះ[redacted]គឺ ឈ្មោះ [redacted] យ៉ុម បានមកធ្វើខ្ទមនៅ



Scanned with CamScanner

លើដីរបស់ឈ្មោះ [redacted] សារេត ហើយគាត់បានឱ្យរើចេញតែឈ្មោះ [redacted] យូម មិនព្រមរើចេញទើបតែថ្មីៗ ឈ្មោះ [redacted] សារេត ចង់ធ្វើព្រំដី និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដី ដោយមានតំណាងពីខាងសាលាស្រុក ខាងឃុំ មន្ត្រីនគរបាលចូលរួមដែរ ហើយបន្តឱ្យឈ្មោះ ណៃ សារេត ដាំបង្គោលលើដីស្រាប់តែ ឈ្មោះ [redacted] យ៉ុំ ,ឈ្មោះ [redacted] យូម ,ឈ្មោះ [redacted] ពេទ្យ ,ឈ្មោះ [redacted] ប៉ោះ ,ឈ្មោះ [redacted] សូរិយា ឈ្មោះ [redacted] ម៉ាប់ និង ឈ្មោះ [redacted] ង៉ា មកតវ៉ា និងបានប្រានឈ្មោះ [redacted] សារេត បណ្តាលឱ្យដួលទៅដល់នឹងដើមស្វាយត្រូវក្បាលផ្នែកខាងក្រោយ។ នៅពេលដែលក្រុមការងារខាងលើបោះបង្គោលព្រំដីរួចហើយ ក៏ត្រឡប់ទៅវិញស្រាប់តែ ឈ្មោះ [redacted] យ៉ុំ និងកូនៗដូចមានឈ្មោះខាងលើមកដកបង្គោលព្រំដីនោះចោលអស់ចំនួន ០៣បង្គោល។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ១៦៩ (ឆ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូង ខេត្តសៀមរាប ដែលមានសេចក្តីសម្រេចដូចតទៅ៖

ក. ផ្តន្ទាទោសលើជនជាប់ចោទ៖

១. ឈ្មោះ [redacted] យ៉ុំ ភេទស្រី អាយុ ៥៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ (មួយ) ឆ្នាំ។

២. ឈ្មោះ [redacted] ពេទ្យ ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគាកំណត់១ (មួយ) ឆ្នាំ។

៣. ឈ្មោះ [redacted] ប៉ោះ ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ (មួយ) ឆ្នាំ។

៤. ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ (មួយ) ឆ្នាំ។

៥. ឈ្មោះ [redacted] ង៉ា ភេទប្រុស អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ (មួយ) ឆ្នាំ។

៦. ឈ្មោះ [redacted] យូម ភេទស្រី អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១ (មួយ) ឆ្នាំ។

៧. ឈ្មោះ [redacted] សូរិយា ភេទស្រី អាយុ ២៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធានាគារកំណត់ ១ (មួយ) ឆ្នាំ។

ពីបទ ហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប កាលពីឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាល។

ខ. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ុំ ,ឈ្មោះ [redacted] ម៉ាប់ ,ឈ្មោះ [redacted] ពេទ្យ ,ឈ្មោះ [redacted] យូម ឈ្មោះ [redacted] ប៉ោះ ,ឈ្មោះ [redacted] ង៉ា និងឈ្មោះ [redacted] សូរិយា រួមគ្នាសងសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារេត ការទាមទារលើសពីនេះបដិសេធចោល។

-**បានឃើញ** ពាក្យបណ្តឹងទាស់ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ុំ ,ឈ្មោះ [redacted] ពេទ្យ ,ឈ្មោះ [redacted] ប៉ោះ ,ឈ្មោះ [redacted] ម៉ាប់ ,ឈ្មោះ [redacted] ង៉ា ,ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] យ៉ា បានសុំប្តឹងទាស់នឹងសាលក្រមលេខ ១៦៩ (ឆ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូង ខេត្តសៀមរាប ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ៧៨"ច.១"/៩០៨ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានសេចក្តីសម្រេចដូចតទៅ៖

សាលាឧទ្ធរណ៍បាត់ដំបង ដែលមានសេចក្ដីសម្រេចដូចតទៅ៖

១. ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ របស់លោក [redacted]សុភ័ក្រ្ត ជាមេធាវី ទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ[redacted] យុំ ,ឈ្មោះ [redacted] ពេទ្យ ,ឈ្មោះ [redacted]ប៉ោះ ,ឈ្មោះ [redacted]ម៉ាប់ និងឈ្មោះ [redacted]ង៉ា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. បដិសេធចោលចំណុច ២.ក.១ ,២.ក.២ ,២.ក.៣ ,២.ក.៤ ,២.ក.៥ ក្នុងសេចក្ដីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ៧៨ "ច.១"/៩០៨ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ និងចំណុច២ លើជនជាប់ចោទឈ្មោះ [redacted] យុំ ឈ្មោះ[redacted]ពេទ្យ ,ឈ្មោះ [redacted] ប៉ោះ ,ឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted]ង៉ា ក្នុងសេចក្ដីសម្រេច នៃសាលក្រមព្រហ្មទណ្ឌលេខ ១៦៩(ឆ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ចោលជាអសារបង់។

៣. ឱ្យឈ្មោះ[redacted]យុំ ,ឈ្មោះ[redacted]ពេទ្យ ,ឈ្មោះ[redacted]ប៉ោះ ,ឈ្មោះ[redacted]ម៉ាប់ និងឈ្មោះ[redacted]ង៉ា រួចខ្លួនពីបទ ហិង្សាលើអ្នកកាន់កាប់លើអចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិព្រលិត ឃុំរើល ស្រុកពួក ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល។

សាលដីកានេះបានបើកសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]យុំ ,ឈ្មោះ [redacted]ពេទ្យ ឈ្មោះ [redacted]ម៉ាប់ និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ប៉ោះ ,ឈ្មោះ [redacted]ង៉ា តែចាត់ទុកជាចំពោះមុខ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] សារេត។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-**បានឃើញ** បណ្ដឹងទាស់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារេត (ជាចុងបណ្ដឹងឧទ្ធរណ៍) បានសុំប្ដឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ: ៣៥២ (ឆ) ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង គ្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេចបញ្ចប់នៃសាលដីកា។

-**បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍បាត់ដំបង។

-**បានឃើញ** សេចក្ដីសន្និដ្ឋានចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអម សាលាឧទ្ធរណ៍បាត់ដំបង។

**នាពេលសវនាការ**

-ក្រឡាបញ្ជីត្រួតពិនិត្យវត្តមាន។

-ជនជាប់ចោទឈ្មោះ[redacted]យុំ (អវត្តមាន)។

-ជនជាប់ចោទឈ្មោះ [redacted] ង៉ា (អវត្តមាន)។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted]ប៉ោះ (អវត្តមាន)។

-ជនជាប់ចោទឈ្មោះ[redacted] ម៉ាប់ (មានវត្តមាន)។

-ជនជាប់ចោទឈ្មោះ[redacted]ពេទ្យ (មានវត្តមាន)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សារេត (មានវត្តមាន)។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ លើកយកតែពីបញ្ហាទម្រង់នៃពាក្យបណ្តឹងឧទ្ធរណ៍មកពិនិត្យ រួចសួរយោបល់តំណាងមហាអយ្យការ និងចៅក្រមប្រឹក្សា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារេត បានឆ្លើយថា ៖ មូលហេតុដែលរូបខ្លួនប្តឹងទាស់ព្រោះខ្លួនមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទេ ព្រោះខ្លួនពិតជាម្ចាស់កម្មសិទ្ធិលើដីនោះពិតប្រាកដមែន ដោយខ្លួនមានលិខិតបញ្ជាក់ស្នាមមេដៃពីមេភូមិ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ បានឆ្លើយថា៖ ខ្លួនសុំឱ្យរក្សាចម្លើយដូចនៅក្នុងសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ នៅដដែល។

-ជនជាប់ចោទឈ្មោះ [redacted] ពេទ្យ បានឆ្លើយថា៖ ខ្លួនសុំឱ្យរក្សាចម្លើយដូចនៅក្នុងសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ នៅដដែល។ ចំពោះឈ្មោះ[redacted] យុំ , ឈ្មោះ [redacted]ង៉ា ,ឈ្មោះ [redacted]ប៉ោះ បានទទួលដំណឹងហើយតែពួកគាត់បានទៅធ្វើពលករនៅប្រទេសថៃហើយ មិនអាចចូលរួមក្នុងសវនាការទេ។

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] យុំ ថា ៖ ខ្លួនប្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងការសម្រេចរបស់សាលាដំបូង ដោយហេតុថាខ្លួនមិនបានប្រព្រឹត្ត ដូចការចោទប្រកាន់ទេ ខ្លួនកាន់កាប់ដីនោះនៅឆ្នាំ១៩៨២ ដែលមានទំហំ ២៩ម×៣០ម ដោយមេភូមិឈ្មោះ [redacted]សន ចែកឱ្យហើយបានកាន់កាប់និងរស់នៅលើដីនោះរហូតដល់សព្វថ្ងៃ។ នៅឆ្នាំ២០១៧ ឈ្មោះ[redacted] សារេត បានហៅសមត្ថកិច្ច និងសុរិយោដីមកចុះវាស់វែង ជាន់លើដីរបស់ខ្លួន ហើយចោទប្រកាន់ថាខ្លួនដកបង្គោលរបងរបស់គេ ខ្លួនមិនធ្វើទេហើយកូនរបស់ខ្លួនក៏មិនបានធ្វើដែរ ខ្លួនរស់នៅលើដីនោះពុំមានឯកសារកាន់កាប់ទេ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមការពិនិត្យឯកសារ និងស្តាប់តាមការលើកឡើងរបស់ប្រធានក្រុមប្រឹក្សា ក្នុងរឿងនេះពិនិត្យឃើញថាត្រូវបានសាលាឧទ្ធរណ៍ សម្រេចសេចក្តីរួចផុតបទចោទ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាស់នឹងសាលដីកាកំបាំងមុខ ដូច្នេះការប្តឹងទាស់នេះមិនអាចទទួលយកបានទេ គប្បី ក្រុមប្រឹក្សាពិចារណា និងសម្រេចតាមផ្លូវច្បាប់។

-សំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted]ពេទ្យ និងឈ្មោះ[redacted]ម៉ាប់៖ សុំតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍បាត់ដំបង ទុកជាបានការ។

-សំណូមពរចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សារេត ៖ សុំឱ្យក្រុមប្រឹក្សាជួយរកយុត្តិធម៌ឱ្យខ្លួនផង។

➢ ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សារេត និងសំណួមពរចុងក្រោយ។

➢ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពេទ្យ និងឈ្មោះ [redacted]ទាប់ និងសំណូមពរចុងក្រោយ។

➢ ក្រោយពីបានស្តាប់អំណាបចម្លើយជនជាប់ចោទឈ្មោះ [redacted]ប៉ុ។

➢ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងមហាអយ្យការ។

➢ ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី។

➢ ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

**១.យល់ឃើញ** ពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សារេត សុំប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ: ៣៥២ (ឥ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលបណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ និងរយៈពេលដែលច្បាប់បានកំណត់ដែលសភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ បាត់ដំបង មានសមត្ថកិច្ច និងសម្រេចសេចក្តីស្របតាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តាមមាត្រា៤១២ ,៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២.យល់ឃើញថា** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សារេត បានឆ្លើយថា ៖ មូលហេតុដែលរូបខ្លួនប្តឹងទាស់ ព្រោះខ្លួនមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទេ ព្រោះខ្លួនពិតជាម្ចាស់កម្មសិទ្ធិលើដីនោះពិតប្រាកដមែន ដោយខ្លួនមានលិខិតបញ្ជាក់ស្នាមមេដៃពីមេភូមិ។

ដែលតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនមានមូលដ្ឋានគ្រប់គ្រាន់ និងពុំមានភស្តុតាងជាឯកសារណាមួយ ឱ្យក្រុមប្រឹក្សាជំនុំជម្រះ យកមកពិចារណាឡើយ ដោយហេតុថាលិខិតអះអាងបញ្ជាក់ពីសាវតាដីមានចុះហត្ថលេខា ដោយមេភូមិព្រលិត និងមេឃុំរើល ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ពុំមែនជាលិខិតយថាភូត ដែលមានតម្លៃគតិយុត្តិ បញ្ជាក់អំពីកម្មសិទ្ធិបានឡើយ។

**៣.យល់ឃើញថា** សំអាងហេតុក្នុងសាលដីកាព្រហ្មទណ្ឌលេខ ៣៥២ (ឥ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង មានមូលដ្ឋានគ្រប់គ្រាន់ហើយ នាំឱ្យសាលាឧទ្ធរណ៍បាត់ដំបងពុំចាំបាច់លើកយកមកសំអាងហេតុជាថ្មីទៀតទេ គប្បី ក្រុមប្រឹក្សាជំនុំជម្រះ រក្សាទុកសំអាងហេតុនេះទុកជាបានការ។

**៥.យល់ឃើញថា** តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ផ្អែកតាមការពិនិត្យឯកសារ និងស្តាប់តាមការលើកឡើងរបស់ប្រធានក្រុមប្រឹក្សា ក្នុងរឿងនេះពិនិត្យឃើញថាត្រូវបានសាលាឧទ្ធរណ៍សម្រេចសេចក្តីរួចផុតបទចោទ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាស់នឹងសាលដីកាក់ព្រាងមុខ ដូច្នេះការប្តឹងទាស់នេះមិនអាចទទួលយកបានទេ គប្បី ក្រុមប្រឹក្សាពិចារណា និងសម្រេចតាមផ្លូវច្បាប់។



Scanned with CamScanner

ដែលតាមសេចក្តីសន្និដ្ឋាននេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ លើកយកមកពិចារណា។

**៦.យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ: ៣៥២ (ឌ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលបានសម្រេចមកនេះ មានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បី ក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍បាត់ដំបង ទុកជាបានការដដែល។

## <u>ហេតុដូច្នេះសម្រេច</u>

១. ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សាវេត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២. តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៣៥២ (ឌ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ទុកជាបានការដដែល។

សាលដីកានេះបានជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ម៉ាប់ ,ឈ្មោះ[redacted]ពេទ្យ ,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សាវេត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យ៉ុំ ,ឈ្មោះ[redacted]ប៉ាះ និងឈ្មោះ[redacted]ដា តែចាត់ទុកជាចំពោះមុខ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

បាត់ដំបង,ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner